KING COUNTY HOUSING AUTHORITY

សេចក្តីជូនដំណឹង ៖ ការផ្លាស់ប្តូរអំពីច្បាប់នៃការជួលផ្ទះមកដល់គ្រួសារដែលមានសមាជិកមានសមត្ថភាពធ្វើការ

ខ្សភា 2011

ក្រុមគ្រួសារ WIN Rent ជាទីរាប់អាន,

នៅខែកក្កដា ឆ្នាំ 2010 គណៈកម្មការស្នងការនៃអាជ្ញាធរផ្ទះរដ្ឋយីងខោនធី (King County Housing Authority Board of Commissioners) បានអនុម័តយល់ព្រមលើកម្មវិធី WIN Rent ដែលជាដំណាក់កាលទី2 នៃគំនិតថ្មីៗ ទៅលើការកែទម្រង់នៃការជួលគេហដ្ឋានរបស់ KCHA ។ WIN Rent ផ្តោតទៅលើក្រុមគ្រួសារមានមនុស្ស ពេញវ័យមួយរូបៗដែលមានការងារធ្វើ ឬមានសមត្ថភាពធ្វើការ។ លោកអ្នកទទួលលិខិតនេះពីព្រោះក្រុម គ្រួសារលោក អ្នកគឺជាក្រុមគ្រួសារ "WIN Rent" ។

អ្វីដែលសំខាន់ KCHA បានជំនួសប្រព័ន្ធថ្នាក់ជាតិ HUD សម្រាប់ការសម្រេចចិត្តដាក់ឲ្យជួលជាមួយច្បាប់ក្នុងតំបន់ដែលអនុញ្ញាតិឲ្យចំណូលរបស់អ្នកជួលឡើងហួសជាងពេលវេលាដែលបានសន្យាដោយគ្មានទទួលនូវផលប ះពាល់ភ្លាមៗទៅនឹងសមាភាគនៃអ្នកជួល។ ទាំងនេះគឺមានគោលបំណងអនុញ្ញាតិឲ្យអ្នកចូលរួមក្នុងកម្មវិធីអាចអាច មានការងារធ្វើនិងមានជម្រើសសម្រាប់ជីវិតដែលអាចឲ្យមានកំណើនចំណូលមានរយៈពេលយូរ និងប្រសិទ្ធិ ភាពផ្ទាល់ខ្លួនកាន់តែប្រសើរជាងមុន។

សម្រាប់ក្រុមគ្រួសារជាច្រើន ថ្លៃឈ្នួលនឹងមិនប្រែប្រួលទៅតាមគោលការណ៍ថ្មីនោះឡើយ។ ក្រុមគ្រួសារច្រើនទៀត នឹងទទួលបានការចុះតម្លៃលើការជួលរបស់ពួកគេ។ ឯខ្លះទៀតនឹងទទួលបានថ្លៃឈ្នួលចុះ និងចំនួនក្រុមគ្រួសារផ្សេងទៀតនឹងទទួលបានការតម្លើងថ្លៃឈ្នួលអាចលើសពី $100 ។ ក្នុងករណីថ្លៃឈ្នួលមានកើនឡើង ដែលអាច**<u>បណ្តាលមកពីការផ្លាស់ប្តូរផ្ទាល់</u>** ពីគោលការណ៍ជួលរបស់ KCHA នោះ KCHA នឹងកម្រិតការជួល និងកំណត់ថ្លៃឈ្នួលមិនឲ្យលើសពី $100 ពីតម្លៃជួលនាពេលបច្ចុប្បន្ន។ ការពិនិត្យលើការជួលនឹងអនុវត្តនៅ**<u>12 ខែដំបូង</u>**បន្ទាប់ពីដំណើរការផ្លាស់ប្តូរទៅកម្មវិធី WIN Rent និងផ្តល់ឲ្យក្រុមគ្រួសារនូវពេលវេលាដើម្បីកែ តម្រូវទៅការជួលខ្ពស់ជាងមុន។ បន្ទាប់ពី 12 ខែ **ការពិនិត្យនឹងត្រូវដកចេញ** ហើយតម្លៃជួលនឹងត្រឡប់ មកជាធម្មតាវិញតាមគោលការណ៍ការគណនាការជួលពិតប្រាកដ។

ទំព័រខាងក្រោមនេះផ្តល់នូវការពន្យល់លម្អិតអំពីគោលការណ៍ជួលថ្មី។

តើគោលបំណងរបស់កម្មវិធី WIN RENT គឺជាអ្វី?

- ✓ ធ្វើឲ្យដំណើរការនៃការគណនាការជួលមានលក្ខណៈសាមញ្ញ និងកាន់តែងាយយល់។
- ✓ បង្កើតច្បាប់សម្រាប់ Section 8 និង កម្មវិធីផ្ទះរដ្ឋសាធារណៈ ឲ្យដូចគ្នា។
- ✓ បង្កើតបំលាស់ប្តូរគោលការណ៍ដែលធ្វើឲ្យប្រាក់ចំណូលកើនឡើង និងមានប្រសិទ្ធភាពសេដ្ឋកិច្ចផ្ទាល់ខ្លួន។

ព័ត៌មាននេះត្រូវបានបកប្រែជាភាសាអេស្ប៉ាញ៉ុល, ខ្មែរ, រុស្ស៊ី, វៀតណាម, ភូរ៉ា និង ស្វូម៉ាលី, ហើយអាចមាននៅតាមការិយាល័យចាត់ចែងអាសនៈទ្រព្យផ្ទះរដ្ឋសាធារណៈ; ការិយាល័យSection 8 ឬតាមអនឡាញអាសយដ្ឋានwww.kcha.org.

តើ WIN RENT មានការផ្លាស់ប្តូរអ្វីខ្លះ?

តារាងខាងក្រោមនេះផ្តល់នូវការសង្ខេបយ៉ាងខ្លីនៃការផ្លាស់ប្តូរគោលការណ៍ជួលរបស់ KCHA ។
សូមអានលិខិតទាំងមូលសម្រាប់ការពន្យល់យ៉ាងលម្អិតនៃការផ្លាស់ប្តូរទាំងអស់នេះ។

សេចក្តីសង្ខេបនៃការផ្លាស់ប្តូរ

ការផ្លាស់ប្តូរ	គោលការណ៍ជួលថ្មី	គោលការណ៍ជួលថ្មីរបស់ WIN RENT
ឈ្មោះនៃការពិនិត្យការជួល	ការពិនិត្យប្រចាំឆ្នាំ	ការពិនិត្យលើការផ្តល់ឲ្យឡើងវិញ
ភាពញឹកញាប់នៃការពិនិត្យការជួលឡើងវិញ	ជារៀងរាល់ឆ្នាំ '2011, 2012, 2013…'	រៀងរាល់ឆ្នាំ**<u>ផ្សេងៗគ្នា</u>** '2011, 2013, 2015…'
ថ្លៃជួលផ្អែកលើ	30% នៃការកែសម្រួលចំណូល	កម្រិតចំណូល
ការជួលជាអប្បបរមា	គ្មាន	$25/ ខែ
ការកាត់បន្ថយចំណូល	ប្រជាជនភាគតិច មនុស្សចាស់ អ្នកពិការ និងគ្រួសារដែលទទួលការឧបត្ថម្ភពីរដ្ឋ	ប្រាក់ឧបត្ថម្ភកុមារ ចំនួនកាត់បន្ថយចាប់ផ្តើមពី$2500 *(ការកាត់បន្ថយផ្សេងៗទៀតបានត្រូវដាក់បញ្ចូលទៅក្នុងចំនួនប្រាក់ចំណូលចំណាត់ក្រុម)*
ចំណូលរបស់សិស្សដែល**ធ្វើការ**	មិនរាប់ប្រសិនសិស្សរៀនពេញម៉ោង	មុខងារសិស្សគឺមិនត្រូវបានពិចារណាទេពេលកំពុងកំណត់ថាតើប្រាក់ចំណូលត្រូវបានរាប់ ឬមិនរាប់
ចំណូលបានមកពីការងារ សម្រាប់សមាជិកគ្រួសារដែលមិនមែនជាមេគ្រួសារ	N/A	• ក្រោមអាយុ 21ឆ្នាំ: ប្រាក់ចំណូលពី**ការងារ**គឺ**<u>មិន</u>**ត្រូវបានរាប់បញ្ចូល • ចាប់ពីអាយុ 21ឆ្នាំឡើង: ប្រាក់ចំណូល**<u>គឺ</u>**ត្រូវបានរាប់បញ្ចូល**<u>ទាំងអស់</u>** ***<u>ចំណាំ</u>***: *រាល់ប្រាក់ចំណូលទាំងអស់ត្រូវបានរាប់សំរាប់មេគ្រួសារ និងប្តីប្រពន្ធ/អ្នកជួលផ្ទះរួមគ្នា ដោយមិនគិតពីអាយុ។*
អ្នកជួលស្នើរនូវការផ្លាស់ប្តូរការជួល	គ្មានកំណត់	កំណត់ត្រឹម2ដង ក្នុងរង្វង់រយៈពេល2ឆ្នាំ
កំណើតប្រាក់ចំណូលដែលបានរាយការណ៍	ការរាយការណ៍ពីការប្រែប្រួលនៅក្នុងប្រាក់ចំណូល	មិនតម្រូវឲ្យរាយការណ៍កំណើននៃប្រាក់ចំណូល ក្នុងករណី : • **<u>ក្រោយ</u>**ពីបានស្នើ និងទទួលការបញ្ចុះតម្លៃ • នៅពេលដែលបញ្ចូលសមាជិកគ្រួសារដែលមានប្រាក់ចំណូល • នៅពេលដែលក្រុមគ្រួសារមានប្រាក់ចំណូល$0 ឬថ្លៃជួលអប្បបរមា
តម្លៃជួលទាបបំផុត (កម្មវិធីផ្ទះរដ្ឋសាធារណៈ) និង កម្មវិធីមិនរាប់បញ្ចូលប្រាក់ចំណូលរកបាន (Earned Income Disregard programs) (កម្មវិធីផ្ទះរដ្ឋសាធារណៈ/កម្មវិធី Section 8) មិនបានបន្ត និងបញ្ចប់នៅពេលការពិនិត្យការជួលលើកក្រោយ។		

តើថ្លៃជួលត្រូវបានគណនាដូចម្តេច?

កម្មវិធី WIN Rent ប្រើប្រាស់ចំណាត់ក្រុមប្រាក់ចំណូល "ចំណាត់ក្រុមប្រាក់ចំណូល - income bands" ដើម្បីបែងចែកជាក្រុមនៃប្រាក់ ចំណូលនៃក្រុមគ្រួសារ និង ធ្វើឲ្យប្រាក់ចំណូលនេះកើនឡើងដោយគ្មានការផ្លាស់ប្តូរក្នុងការជួលប្រចាំខែ។ ក្រុមគ្រួសារភាគច្រើននឹងបង់ទៅតាមកម្មវិធី WIN Rent ចំនួន 28.3% នៃ ប្រាក់ចំណូលចំពោះថ្លៃជួល។ ប្រាក់ចំណូលនៅក្នុងក្រុមគ្រួសារកាន់តែខ្ពស់ភាគរយនៃប្រាក់ចំណូលដែលនឹង ត្រូវបានប្រើប្រាស់ចំពោះការជួលកាន់តែទាប។ តារាងខាងក្រោមនេះបង្ហាញពីការបែងចែកនៃក្រុមប្រាក់ចំណូល និងថ្លៃជួលសរុបជាមួយក្រុមនីមួយៗ:

ក្រុមប្រាក់ចំណូលសំរាប់គ្រួសារ		
ប្រាក់ចំណូលប្រចាំឆ្នាំកែសំរួល	អ្នកជួលផ្ទះ ជួលដុល= សរុបចំនួនដែលអ្នកជួលផ្ទះបង់ (TTP)	ការពន្យល់អំពីក្រុមប្រាក់ចំណូល
		$1,000 កំរិតកើនដល់ $10,000 ។ ការជួលត្រូវកំណត់ 28.3% នៃកំរិតទាបបំផុតនៃក្រុមនីមួយៗ។
		ឧទាហរណ៍ ក្រុមគ្រួសារមានបន្ទប់គេង 2 $6,000 ប្រាក់ចំណូលប្រចាំឆ្នាំ = ប្រាក់ចំណូលប្រចាំខែ $500 $500 x 28.3% = $142 ដក ការប្រើប្រាស់ថាមពល = $52* **ថ្លៃជួល = $90 ($142 – $52)**
តិចជាង $1,000	0	*ឧបមាថា អគ្គិសនីក្រុង Seattle និង ទឹក/ទឹកស្អុយ បង់ដោយម្ចាស់ផ្ទះ។ គ្មានការផ្លាស់ប្តូរនៅក្នុងការជួលរហូតដល់ប្រាក់ចំណូលក្រុមគ្រួសារកើនឡើងដល់ $7,000 ឬខ្ពស់ជាង។*
1,000 - 1,999	24	
2,000 - 2,999	47	
3,000 - 3,999	71	
4,000 - 4,999	94	
5,000 - 5,999	118	
6,000 - 6,999	142	
7,000 - 7,999	165	
8,000 - 8,999	189	
9,000 - 9,999	212	
10,000 - 12,499	236	*$2,500* ជាកំណើនខាងចំណូលដើម្បីអនុញ្ញាតឲ្យពួកគេចាប់ផ្តើមទាញ យកចំណេញពីការសន្សំជាកំណើននៃចំណូល
12,500 - 14,999	295	
15,000 - 17,499	354	
17,500 - 19,999	413	
20,000 - 22,499	472	
22,500 - 24,999	531	
25,000 - 29,999	590	ការកើនដល់ $5,000 ជាកំណើនប្រាក់ចំណូល និងគ្រួសារចាប់ផ្តើមបាត់បង់សិទ្ធិសម្រាប់ កម្មវិធីជំនួយដូចជាជំនួយមើលមើលថែទាំកុមារជាដើម។
30,000 - 34,999	708	
35,000 - 39,999	825	
40,000 - 44,999	943	
45,000 - 49,999	1,061	
50,000 - 54,999	1,179	
55,000 - 59,999	1,297	
60,000 - 64,999	1,415	
65,000 - 69,999	1,533	
70,000 - 74,999	1,651	
$75,000+	ចូរមើលកំណត់សំគាល់ខាងក្រោម	

របៀបប្រើប្រាស់តារាងនេះ:

1. ចូរកំណត់ប្រាក់ចំណូលប្រចាំឆ្នាំកែសំរួល (annual adjusted income)
2. ចូររក ប្រាក់ចំណូលប្រចាំឆ្នាំកែសំរួល នៅក្នុងកម្រិតប្រាក់ចំណូលមាននៅក្នុងជួរឈរខាងឆ្វេង
3. ចូរប្តូរដោយកាត់ជួរដេកទៅជួរឈរខាងស្តាំ ដើម្បីគណនាការជួលសរុបរបស់អ្នកជួល។

4. ចូរដកការប្រើប្រាស់ថាមពល (ប្រាក់ជំនួយលើថ្លៃទឹក) ពីការទូទាត់សរុបរបស់អ្នកជួលដើម្បីកំណត់ចំនួនថ្លៃជួល។ ការប្រើប្រាស់ថាមពលគឺមិនត្រូវបានបង្ហាញនៅទំព័រនេះទេ។

សំគាល់: (1) គ្រួសារទាំងឡាយដែលមានប្រាក់ចំណូលប្រចាំឆ្នាំដុល (Gross Annual Income) ចំនួន $75,000 ឬច្រើនជាងនេះ នឹងទទួលបានថ្លៃឈ្នួលឡើង 28.3% នៃប្រាក់ចំណូលប្រចាំខែដុល (Gross Monthly Income) ដែលតិចជាងជំនួយបន្ថែមថាមពល (Energy Assistance Supplement) (2) ចំនួនថ្លៃជួលតាមបញ្ជីហិរញ្ញវត្ថុចម្រុះរបស់ KCHA (KCHA Mixed Finance) បញ្ជាក់លើការប្រើប្រាស់តាមរយៈកម្មវិធីឥណទានពន្ធជារសំរាប់គ្រួសារមានប្រាក់ចំណូលទាប (Low Income Housing Tax Credit - LIHTC) ដែលអាចកំណត់ដោយស្ថាប័នឥណទានពន្ធជារ (established Tax Credit) ទៅលើការជួលជាអតិបរមាសម្រាប់គ្រួសារដែលមានប្រាក់ចំណូលលើសពីកំរិតខ្ពស់បំផុតរបស់ LIHTC។

តើជាការជួលត្រូវបានគណនាជារៀយៗយ៉ាងដូចម្តេច?

ការជួលនឹងត្រូវបានគណនារៀងរាល់ 2ឆ្នាំម្តង។ ពត៌មានប្រមូលកំឡុងពេល<u>ការធ្វើលិខិតបញ្ជាក់ឡើងវិញ</u> និង បញ្ជូលការសំខាន់តិចតួចដើម្បីបញ្ជាក់បន្តសម្រាប់ក្រុមគ្រួសារដើម្បីចូលរួមកម្មវិធី និងដើម្បីបញ្ជាក់នូវកាតព្វកិច្ចនៃក្រុមគ្រួសារនីមួយៗ។ នៅពេលការជួលគឺត្រូវបានធ្វើឡើងកំឡុងពេលការធ្វើលិខិតបញ្ជាក់ឡើងវិញ អត្រាជួលគឺនៅដដែលរហូតដល់ការធ្វើលិខិតបញ្ជាក់ឡើងវិញបានចុះបញ្ជី 2ឆ្នាំក្រោយ ឬរហូតដល់កាលៈទេសៈ ណាមួយដើម្បីរង់ចាំឬក៏ការកែតម្រូវការជួលជាពិសេសណាមួយ។

ការជួលជាអប្បបរមា

កម្មវិធី WIN Rent របស់ KCHA នឹងមានថ្លៃឈ្នួលទាបបំផុត $25/ខែ។

តើមានអ្វីកើតឡើងនៅពេលការគណនាថ្លៃជួលទាបជាង $25/ខែ?		
6ខែដំបូង	→	ការជួលអាស្រ័យលើការគណនាថ្លៃជួល (ក្រុមគ្រួសារមិនចាំបាច់បង់នូវថ្លៃជួលជាអប្បបរមា)
បន្ទាប់ពី6ខែដំបូង	→	ការជួលនឹងត្រូវកំណត់ថ្លៃជួលទាបបំផុត $25
គ្រួសារទាំងមិនអាចបង់ថ្លៃជួលទាបបំផុតត្រឹម$25 បន្ទាប់ពី 6ខែ	→	សិទ្ធក្នុងការដាក់ពាក្យស្នើសុំការលើកលែងក្រោម Hardship Policy ដែលបង្កើតឡើងដោយ KCHA
ក្រុមគ្រួសារណាដែលគ្មានប្រាក់ចំណូលតម្រូវឲ្យរាយការណ៍ការផ្លាស់ប្តូរប្រាក់ចំណូលជារៀងរាល់ត្រីមាស រហូតដល់ប្រាក់ចំណូលរបស់ក្រុមគ្រួសារមានឡើងវិញ។		

ចំណាយលើការថែទាំក្មេង

គោលការណ៍ WIN Rent របស់ KCHA អនុញ្ញាតិឲ្យក្រុមគ្រួសារនូវទឹកប្រាក់**ទាបបំផុត $2,500** សម្រាប់ការថែទាំក្មេង ដើម្បីមានសិទ្ធិសម្រាប់ការកាត់បន្ថយនៅក្នុងការជួល។ ការកាត់បន្ថយការថែទាំក្មេង គឺធ្វើទៅបានទៅតាមចំនួនខាងក្រោម:

ការចំណាយប្រាក់ផ្ទាល់ខ្លួន		ការកាត់បន្ថយប្រាក់ចំណូល
$2,500-$4,999	→	$2,500
$5,000-$7499	→	$5,000
$7,500-$9,999	→	$7,500
$10,000 and over	→	$10,000

គ្រួសារដែលមានបើក**ទារកកន្លានក្នុងផ្ទះ** (In-Home Childcare Facility) មានលទ្ធភាពអាចផ្តល់ការថែរក្សាសំរាប់សមាជិកក្រុមគ្រួសាររបស់គេផ្ទាល់ **និងគ្មានសិទ្ធិ** សម្រាប់ការកាត់បន្ថយពីប្រាក់ចំណូលដុលដែលស្ថិតក្រោមការវិនិច្ឆ័យនេះទេ។ ជាបន្ថែម លើនេះការកាត់បន្ថយនេះ **នឹងមិនអាចមាន** សម្រាប់ក្រុមគ្រួសារដែលមាន **ប្រាក់ចំណូលលើសពី $75,000 ។**

ការដកចេញចំពោះចំណូលពីការធ្វើការសម្រាប់សមាជិកគ្រួសារដែលមានអាយុក្រោម 21 ឆ្នាំ

ដើម្បីលើកទឹកចិត្តដល់ការបញ្ចប់ការអប់រំកម្រិតខ្ពស់ និងតម្រូវការសម្រាប់រាយការណ៍ទូវកម្មវិធីយ៉ាងសាមញ្ញកម្មវិធី WIN Rent របស់ KCHA **មិនរាប់បញ្ចូល**ប្រាក់ចំណូលការងារបានមកពីការគណនាថ្លៃឈ្នួលនៃគ្រប់សមាជិកគ្រួសារទាំងអស់ដែលមាន**អាយុក្រោម 21 ឆ្នាំ** (មេគ្រួសារផ្សេងទៀត និងប្តី ឬប្រពន្ធ ឬក៏អ្នកជួលរួមគ្នា) មិនគិតដល់ថាតើពួកគេកំពុង ឬមិនកំពុងចុះឈ្មោះក្នុងកម្មវិធីអប់រំ។ ចំណូល**<u>ទាំងអស់</u>**ដែលបានមកពីសមាជិកគ្រួសារដែលមានអាយុ21ឆ្នាំ និងចាស់ជាងនេះ គឺត្រូវបាន**រាប់បញ្ចូល**នៅពេលធ្វើការគណនាថ្លៃឈ្នួល។

ការផ្លាស់ប្តូររបាយការណ៍នៅក្នុងចំណូល និងសមាសភាពគ្រួសារ

អ្នកជួលបានស្នើការផ្លាស់ប្តូរ

ក្រោមកម្មវិធី WIN Rent ក្រុមគ្រួសារអាចស្នើសុំការពិនិត្យឡើងវិញ<u>រហ្វូតដល់ 2ដង</u> នៅក្នុងរង្វង់ការធ្វើលិខិតបញ្ជាក់ឡើងវិញរយៈពេល 2ឆ្នាំ។ ប្រសិនបើបានស្នើ KCHA នឹងបំពេញទូវទម្រង់ "សំណើរបស់អ្នកជួល - tenant-request" តាមការវិនិច្ឆ័យខាងក្រោម:

របាយការណ៍របស់អ្នកជួល:	**KCHA** បំពេញការពិនិត្យឡើងវិញបណ្តោះអាសន្ន បើការផ្លាស់ប្តូរ:
សមាជិកក្រុមគ្រួសារផ្លាស់ចេញ	លទ្ធផលនៃ<u>ការថយចុះ</u>ចំណូល<u>ក្រោម</u>ក្រុមប្រាក់ចំណូលបច្ចុប្បន្ន
ការថយចុះចំណូលនៅក្នុងក្រុមគ្រួសារកំពុងមាន	លទ្ធផលនៃការថយចុះចំណូលក្រោមក្រុមចំណូលបច្ចុប្បន្ន
ការកើនឡើងនៃចំណាយលើការថែទាំកុមារដែលមិនបានបង់	គឺច្រើនជាង $2,000 នៅពេលដែលការចំណាយការថែទាំក្មេងសរុប <u>លើសពី $2,500</u>

ការស្វែងរកកំហុសគ្គង ការមិនបានបង្ហាញ និងការបំភាន់នឹងចេញជាលទ្ធផលក្នុងការផ្លាស់ប្តូរគ្រប់ពេលតាមរបក

គំហើញនានា។ ការផ្លាស់ប្តូរការជួលរបស់អ្នកជួលដែលបានស្នើសុំ នឹងមានប្រសិទ្ធភាពនៅក្នុង របៀបខាងក្រោម:

ការផ្លាស់ប្តូរបានរាយការណ៍	កាលបរិច្ឆេទជាធរមាន	ឧទាហរណ៍
នៅ ឬមុនថ្ងៃទី 22 នៃខែ	ថ្ងៃទី 1 នៃខែតាមបំលាស់ប្តូរខែ ត្រូវបានរាយការណ៍	បំលាស់ប្តូររាយការណ៍: ថ្ងៃទី1-22 តុលា ប្រសិទ្ធិភាព: ថ្ងៃទី 1 ខែវិច្ឆិកា
នៅ ឬបន្ទាប់ពីថ្ងៃទី 23 នៃខែ	ថ្ងៃទី 1 នៃខែទី 2 តាមបំលាស់ប្តូរខែ ត្រូវបានរាយការណ៍	ការរាយការណ៍អំពីបំលាស់ប្តូរ: ថ្ងៃទី 23-31 តុលា ប្រសិទ្ធិភាព: ថ្ងៃទី 1 ខែធ្នូ

បំលាស់ប្តូរក្រុមគ្រួសារតំរូវឲ្យរាយការណ៍ទៅ KCHA

ក្រុមគ្រួសារ**ត្រូវតែ**រាយការណ៍តាមការផ្លាស់ប្តូរក្នុងរយៈពេល 30ថ្ងៃ នៅពេលមានការផ្លាស់ប្តូរ:

ក្រុមគ្រួសារត្រូវតែរាយការណ៍:	ចំណាត់ការរបស់ KCHA:
រាល់ក្រុមគ្រួសារទាំងអស់ដែលមានប្រាក់ចំណូលកើនឡើង **ក្រោយ**ពី KCHA បានបំពេញនូវទម្រង់ដើម្បីកាត់បន្ថយការជួល	KCHA នឹងត្រួតពិនិត្យគ្រប់ចំណូលក្រុមគ្រួសារនិង គណនាថ្លៃឈ្នួលឡើងវិញ។ ក្រុមគ្រួសារត្រូវតែបន្តរាយការណ៍នូវការកើនឡើងនៃប្រាក់ចំណូលរហូតដល់ការផ្លាស់ប្តូរទាំងអស់នេះ ជាហេតុដែលចំណែកការជួលរបស់ក្រុមគ្រួសារកើនឡើង។KCHA នឹងកត់សំគាល់ក្រុមគ្រួសារ នៅពេលពួកគេមិនត្រូវការរាយការណ៍អំពីកំណើនទាំងនេះ។
សមាជិកក្រុមគ្រួសារបន្ថែម	លើកទី1: ក្រុមគ្រួសារត្រូវតែទទួលបានការយល់ព្រមពី KCHA មុនពេលសមាជិកថ្មីអាចក្លាយជាផ្នែកមួយនៃក្រុមគ្រួសារ។ លើកទី 2: KCHA នឹងបញ្ជាក់នូវប្រាក់ចំណូលរបស់សមាជិកថ្មី (ដែលអាចអនុវត្តបាន) និងធ្វើការគណនាឡើងវិញនូវថ្លៃឈ្នួលដោយរាប់បញ្ចូលប្រាក់ចំណូលរបស់សមាជិកថ្មី។ ថ្លៃឈ្នួលនឹងកើនឡើងប្រសិនបើប្រាក់ចំណូលសរុបរបស់ក្រុមគ្រួសារធ្លាក់ចុះចូលក្រុមប្រាក់ចំណូលសរុបដែលកែតម្រូវរួចថ្មី។
ក្រុមគ្រួសារដែលកំពុងបង់ថ្លៃឈ្នួលយ៉ាងតិច $25/ខែ ឬតិចជាងនេះ ត្រូវតែរាយការណ៍ នូវរាល់ការផ្លាស់ប្តូរ ប្រាក់ចំណូលទាំងអស់	KCHA នឹងកំណត់នូវបំលាស់ប្តូរប្រាក់ចំណូលនិងដំណើរការ គណនាថ្លៃឈ្នួលរហូតដល់ក្រុមគ្រួសារបង់ច្រើនជាង $25/ខែនៅក្នុងការជួល។

គោលការណ៍សម្រាប់អ្នកជួបការលំបាក

KCHA បានបង្កើតគោលការណ៍មួយសម្រាប់អ្នកជួបការលំបាកដើម្បីការពារគ្រួសារដែលជួបវិបត្តិ និងដើម្បី កំណត់ករណីដាច់ដោយឡែក និងមិនអាចគ្រោងទុកដែលអាចនឹងកើតឡើងដែលជាលទ្ធផលនៃការផ្លាស់ប្តូរនៅក្នុងគោលនយោបាយជួល។

ការស្នើសុំពត៌មានអំពីលក្ខណៈនៃការលំបាកលំបិន អាចរកបាននៅការិយាល័យចាត់ចែងអចលនទ្រព្យផ្ទះសាធារណៈ Section 8 ឬតាមគេហទំព័រ: www.kcha.org ។

សូមអរគុណ សម្រាប់ការចំណាយពេលវេលាក្នុងការអានពត៌មាននេះ។ យើងសង្ឃឹមថាការផ្លាស់ប្តូរទាំងនេះ ធ្វើឲ្យដំណើរការនៃការជួលងាយស្រួលយល់ មានលក្ខណៈសាមញ្ញក្នុងអនុវត្ត និងបង្កើតនូវឱកាសបន្ថែម ផ្សេងទៀតសម្រាប់កំណើនប្រាក់ចំណូល និងជម្រើសពង្រីកផ្ទះសម្បែង។

ដោយសេចក្ដីរាប់អាន

អាជ្ញាធរផ្ទះរដ្ឋយីងខោនធី